# សេចក្ដីជូនដំណឹង
# ស្ដីពី
# ការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា
# ដើម្បីបម្រើការងារនៅអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវការជ្រើសរើស**បុគ្គលិកជាប់កិច្ចសន្យាផ្នែកវិភាគថវិកា** ដែលមានជំនាញវិភាគ និងមានសមត្ថភាពការងាររដ្ឋបាល។ បេក្ខជន និងបេក្ខនារី ដែលត្រូវបានជ្រើសរើសនឹងត្រូវបម្រើការងារនៅអគ្គនាយកដ្ឋានថវិកា និងត្រូវបំពេញការងារដូចមានចែងក្នុងលក្ខខណ្ឌការងារ ដូចខាងក្រោម៖

- **ប្រភេទ:** វិស័យសាធារណៈ/ការរៀបចំថវិកា/ ការអនុវត្តថវិកា/ ការតាមដាននិងវាយតម្លៃសមិទ្ធកម្ម
- **ទីតាំង:** រាជធានីភ្នំពេញ
- **កាលវិភាគ:** ការងារពេញម៉ោង
- **ប្រាក់បៀវត្ស:** $500 - $900

## ភារកិច្ចសំខាន់ៗ

១). ពិនិត្យនិងផ្ដល់យោបល់លើរចនាសម្ព័ន្ធកម្មវិធី និងសូចនាករ (ឆ្នាំ N) របស់ក្រសួង ស្ថាប័ន ដើម្បីជាកម្មវត្ថុនៃការកែលម្អក្នុងការរៀបចំគម្រោងថវិកាឆ្នាំ N+1

២). ពិនិត្យនិងផ្ដល់យោបល់លើផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ន ដោយផ្ដោតលើការផ្សារភ្ជាប់កម្មវិធីរបស់ក្រសួង ស្ថាប័នជាមួយនឹងអាទិភាពជាតិ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, ភាពឆ្លើយតបនៃការរៀបចំរចនាសម្ព័ន្ធកម្មវិធី និងសូចនាករសមិទ្ធកម្ម

៣). ពិនិត្យនិងផ្ដល់យោបល់លើសំណើថវិការបស់ក្រសួង ស្ថាប័ន តាមរយៈការផ្ទៀងផ្ទាត់ទៅនឹងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ន, ទំនាក់ទំនងនៃកម្មវិធី, រចនាសម្ព័ន្ធកម្មវិធី, និងភាពត្រឹមត្រូវនៃការប្រើប្រាស់សូចនាករសមិទ្ធកម្ម

៤) ចូលរួមកិច្ចប្រជុំចរចាថវិកាប្រចាំឆ្នាំទាំងកម្រិតបច្ចេកទេស និងកម្រិតថ្នាក់ដឹកនាំ

៥). រៀបចំកិច្ចប្រជុំអំពីសមិទ្ធកម្ម ជាមួយនឹងក្រសួង ស្ថាប័ន ព្រមទាំងផ្ដល់ធាតុចូលលើរចនាសម្ព័ន្ធកម្មវិធី និងការប្រើប្រាស់សូចនាករសមិទ្ធកម្ម

៦). ធ្វើការតាមដានជាប្រចាំលើសមិទ្ធកម្មកម្មវិធី តាមរយៈការពិនិត្យឡើងវិញលើរបាយការណ៍សមិទ្ធកម្ម ដែលរៀបចំឡើងដោយក្រសួង ស្ថាប័ន ធៀបនឹងផែនការដែលបានដាក់ចេញ

៧). រៀបចំទម្រង់ (Templates) ឬប៉ាណូឡិកា (Dashboard) សម្រាប់ការតាមដានសមិទ្ធកម្ម

៨). ចូលរួមរៀបចំ និងកែសម្រួលបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការអនុវត្តថវិកា

៩). ចូលរួមរៀបចំជារបាយការណ៍តួលេខ ស្ដីពីការអនុវត្តថវិកា ទៅតាមតម្រូវការចាំបាច់របស់អង្គភាព

១០). ជួយសម្របសម្រួលការងាររដ្ឋបាល និងការងារដទៃទៀតតាមការប្រគល់ភារកិច្ចរបស់ថ្នាក់ដឹកនាំនាយកដ្ឋាន

## លក្ខខណ្ឌ និង គុណវុឌ្ឍិ

១). ជាជនជាតិខ្មែរ

២). មានសញ្ញាបត្របរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ច, គោលនយោបាយសាធារណៈ, ហិរញ្ញវត្ថុសាធារណៈ, រដ្ឋបាលសាធារណៈ, ហិរញ្ញវត្ថុ, គណនេយ្យ ឬជំនាញប្រហាក់ប្រហែល, ព័ត៌មានវិទ្យា, ច្បាប់

៣). មានបទពិសោធន៍ការងារផ្នែកតាមដាននិងវាយតម្លៃ (M&E), ការគ្រប់គ្រងទិន្នន័យ, ហិរញ្ញវត្ថុសាធារណៈ, គណនេយ្យសាធារណៈ ឬបទពិសោធន៍ប្រហាក់ប្រហែល កាន់តែប្រសើរ

៤). មានជំនាញវិភាគ និងសមត្ថភាពក្នុងការសិក្សាស្រាវជ្រាវ

៥). មានជំនាញក្នុងការទំនាក់ទំនងបានល្អ ព្រមទាំងមានស្មារតីសហការក្នុងការធ្វើការងារជាក្រុម

៦). មានចំណេះដឹងស្ទាត់ជំនាញផ្នែកភាសាខ្មែរ និងភាសាអង់គ្លេស ព្រមទាំងមានជំនាញលើការប្រើប្រាស់កម្មវិធី Ms Office

៧). មានសមត្ថភាពធ្វើការក្រោមសម្ពាធពេលវេលា

៨). ត្រូវមានអត្តចរិតល្អ និងសុចរិតភាព ព្រមទាំងមានសមត្ថភាពក្នុងការសម្របខ្លួនទៅនឹងការធ្វើការងារក្នុងវិស័យសាធារណៈ។

## រយៈពេលនៃកិច្ចសន្យាការងារ

កិច្ចសន្យាការងារមានរយៈពេល ១ ឆ្នាំ (រួមបញ្ចូលទាំងការសាកល្បងការងាររយៈពេល ៦ ខែ) ហើយលទ្ធភាពនៃការបន្តកិច្ចសន្យាការងារនឹងត្រូវធ្វើឡើង ផ្អែកតាមសមិទ្ធកម្មការងាររបស់បុគ្គលិក។

## នីតិវិធីនៃការដាក់ពាក្យ

បេក្ខជន និងបេក្ខនារីដែលមានចំណាប់អារម្មណ៍ សូមផ្ញើប្រវត្តិរូបសង្ខេប (CV) ដោយមានភ្ជាប់នូវរូបថត, Cover Letter, សញ្ញាបត្រពាក់ព័ន្ធ និងអត្តសញ្ញាណប័ណ្ណ មកកាន់អាសយដ្ឋានអេឡិចត្រូនិច៖ dme.gdb@gmail.com ឱ្យបានយូរបំផុតត្រឹម***ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៥ ម៉ោង ៥ ល្ងាច។*** សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមធ្វើការទាក់ទងទៅលោកស្រី ឡាយ សុភ័ក្ត្រ តាមរយៈលេខទូរស័ព្ទ៖ 012 545 009 ។

បេក្ខជន និងបេក្ខនារី ដែលជាប់ក្នុងវគ្គជម្រុះបឋម នឹងត្រូវអញ្ជើញមកធ្វើតេស្តសរសេរ និងសម្ភាសន៍ផ្ទាល់មាត់។